គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
**លេខាធិការដ្ឋាន**

លេខ: ០៤៤៧៧/គ.ជ.អ.ប

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ ៦ ឆ្នាំ២០១៣

**គោរពជូន**
**ឯកឧត្តមអភិបាលរាជធានី ខេត្ត**

**កម្មវត្ថុ:** ស្តីពីការពង្រឹងការទទួលខុសត្រូវ និងភាពម្ចាស់ការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

តបតាមកម្មវត្ថុដូចមានចែងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមមេត្តាជ្រាបថា កន្លងមកនេះ ការចាត់ចែង និងការសម្របសម្រួលអនុវត្ត ផអ៣ នៅថ្នាក់រាជធានី ខេត្ត មិនត្រូវបានរៀបចំអនុវត្តពេញលេញក្នុងក្របខ័ណ្ឌនៃការទទួលខុសត្រូវរបស់រចនាសម្ព័ន្ធ និងប្រព័ន្ធការងារនៅតាមទីចាត់ការ និងអង្គភាពនានានៃរដ្ឋបាលរាជធានី ខេត្តនៅឡើយ។ ស្ថានភាពនេះបានឆ្លុះបញ្ចាំងឲ្យឃើញនូវបញ្ហាប្រឈមគួរឲ្យព្រួយបារម្ភពាក់ព័ន្ធនឹងភាពជាម្ចាស់ និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

ដើម្បីធានាដល់ការពង្រឹងភាពជាម្ចាស់ ការទទួលខុសត្រូវផ្នែកស្ថាប័ន និងធានានិរន្តរភាពនៃការអនុវត្តកិច្ចដំណើរការកំណែទម្រង់សម្រាប់រយៈពេលពីមធ្យមទៅរយៈពេលវែង ចាប់ពីឆ្នាំ២០១៤ នេះតទៅ រដ្ឋបាលរាជធានី ខេត្តត្រូវរំសាយក្រុមការងារផអ៣ ដែលមានស្រាប់ ហើយត្រូវប្រគល់ការងារ និងការទទួលខុសត្រូវក្នុងការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំទៅក្នុងទីចាត់ការនានា ចំណុះរដ្ឋបាលរាជធានី ខេត្តស្របទៅតាមតួនាទី ភារកិច្ចរបស់ទីចាត់ការនីមួយៗ។

ដើម្បីធានាបាននូវការសម្របសម្រួល គ្រប់គ្រង និងអនុវត្តសកម្មភាពមានភាពរលូន និងមានការទទួលខុសត្រូវ លេខាធិការដ្ឋាន គ.ជ.អ.ប សូមធ្វើការកំណត់ដូចខាងក្រោម៖

១- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក គឺជាអ្នកទទួលខុសត្រូវទាំងស្រុងចំពោះការសម្របសម្រួល ការគ្រប់គ្រង និងការអនុវត្តសកម្មភាពនានារបស់ ផអ៣ ឱ្យមានភាពរលូន និងមានប្រសិទ្ធភាពក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

២- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក អាចធ្វើការប្រគល់សិទ្ធដល់នាយករដ្ឋបាលនៃសាលារាជធានី ខេត្ត ក្រុង ស្រុករបស់ខ្លួន ដើម្បីដឹកនាំ សម្របសម្រួលការអនុវត្តការងារប្រចាំថ្ងៃបាន។

៣- សកម្មភាពនានាបានលើកឡើងក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់រាជធានី ខេត្តត្រូវប្រគល់ជូនទីចាត់ការដែលមានភារកិច្ចពាក់ព័ន្ធនឹងសកម្មភាពនោះជាអ្នកទទួលខុសត្រូវ។ ...

ដូចគ្នានេះផងដែរ ចំពោះរដ្ឋបាលក្រុង ស្រុក គ្រប់សកម្មភាពដែលនឹងរៀបចំឡើងតាមរយៈ សេចក្តីសម្រេចរួមរវាងរដ្ឋបាលខេត្ត និងរដ្ឋបាលក្រុង ស្រុក ក៏ត្រូវកំណត់ពីការិយាល័យដែលមានការពាក់ព័ន្ធនឹងសកម្មភាពនោះជាអ្នកទទួលខុសត្រូវឱ្យបានច្បាស់លាស់ផងដែរ។

៤- នាយកទីចាត់ការនីមួយៗនៃរដ្ឋបាលរាជធានី ខេត្ត មានភារកិច្ចជាអ្នកធ្វើសំណើសុំគោលការណ៍អនុវត្តសកម្មភាពនានាដែលបានកំណត់ក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ ជាក់ជូនទៅអភិបាលរាជធានី ខេត្ត តាមរយៈនាយករដ្ឋបាលរាជធានី ខេត្ត។ ចំពោះ ថ្នាក់រដ្ឋបាលក្រុង ស្រុក ប្រធានការិយាល័យនីមួយៗនៃរដ្ឋបាលក្រុង ស្រុក មានភារកិច្ចជាអ្នកស្នើសុំគោលការណ៍អនុវត្តសកម្មភាពទៅអភិបាលក្រុង ស្រុក តាមរយៈនាយករដ្ឋបាលក្រុង ស្រុក ដោយផ្អែកតាមសេចក្តីសម្រេចរួមរវាងរដ្ឋបាល ខេត្តជាមួយរដ្ឋបាលក្រុង ស្រុក ។

៥- ករណីរាជធានី ខេត្តពុំមានលទ្ធភាពចាត់ចែងមន្ត្រីរបស់ខ្លួនតាមតម្រូវការងារ អភិបាលរាជធានី ខេត្ត អាចរក្សាមន្ត្រីរាជការដែលមានបទពិសោធន៍ការងារពាក់ព័ន្ធនឹងជំនាញពីបណ្តាមន្ទីរនានាជុំវិញរាជធានី ខេត្ត ឱ្យបន្តទទួលបន្ទុកអនុវត្តសកម្មភាពនោះជំនួសមន្ត្រីរបស់ទីចាត់ការនានារបស់សាលារាជធានី ខេត្ត បណ្តោះអាសន្នបាន។ ប៉ុន្តែ អភិបាលរាជធានី ខេត្ត អាចធ្វើសេចក្តីសម្រេចចាត់តាំងមន្ត្រីរាជការមកពីមន្ទីរនានាឱ្យជួយបំពេញការងារជំនួសមន្ត្រីរបស់ទីចាត់ការនីមួយៗបាន លុះត្រាតែមានការស្នើសុំពីសាមីខ្លួន និងមានការឯកភាពពីប្រធានមន្ទីរសាមីមន្ត្រីរាជការនោះ។

៦- មន្ត្រីគ្រប់ទីចាត់ការ និងការិយាល័យរបស់រាជធានី ខេត្ត ក្រុង ស្រុក ដែលត្រូវបានចាត់តាំងឱ្យបំពេញបេសកកម្មអនុវត្តសកម្មភាពដែលមានការពាក់ព័ន្ធនឹង ផអ៣ សុទ្ធតែមានសិទ្ធទទួលបាននូវប្រាក់ឧបត្ថម្ភបេសកកម្ម។

៧- ក្នុងគោលបំណងពង្រឹងភាពជាម្ចាស់ និងការទទួលខុសត្រូវរបស់រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលក្រុង ស្រុក ដើម្បីគាំទ្រដល់រដ្ឋបាលឃុំ សង្កាត់ លេខាធិការដ្ឋាន គ.ជ.អ.ប បានធ្វើការពិនិត្យ កែសម្រួល នូវមុខតំណែងមួយចំនួនសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ដូចខាងក្រោម៖

<u>ថ្នាក់រាជធានី ខេត្ត៖</u>

ក/-មុខតំណែងដែលរក្សាទុក

១- ទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់រាជធានី ខេត្ត (PPMA)

២- ទីប្រឹក្សាហិរញ្ញវត្ថុថ្នាក់រាជធានី ខេត្ត (PFA)

៣- ទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធថ្នាក់រាជធានី ខេត្ត (PIA)

៤- បុគ្គលិកសម្របសម្រួលក្រុមប្រឹក្សាថ្នាក់រាជធានី ខេត្ត

៥- មន្ត្រីព័ត៌មានវិទ្យាថ្នាក់រាជធានី ខេត្ត

៦- ជំនួយការការិយាល័យ/គណនេយ្យ

៧- អ្នកបើកបរ។

ខ/-មុខតំណែងដែលត្រូវកាត់បន្ថយចំនួន

មុខតំណែងទីប្រឹក្សាអភិវឌ្ឍន៍សមត្ថភាពថ្នាក់រាជធានី ខេត្ត (PCDA) ត្រូវបានកាត់បន្ថយពីចំនួន ៣២ រូប ទូទាំងប្រទេសមកត្រឹម ២២ រូប សម្រាប់ទូទាំងប្រទេស ដោយរក្សាទុក ០១ រូប សម្រាប់ ០១ រាជធានី ខេត្ត លើកលែងតែខេត្តកែប និងខេត្តប៉ៃលិន ដែលការទទួលខុសត្រូវនៃមុខតំណែងនេះត្រូវផ្តល់ឱ្យទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់រាជធានី ខេត្ត (PPMA) ជាអ្នកទទួលបន្ទុក។

គ/-មុខតំណែងដែលលុបចោល

មុខតំណែងទីប្រឹក្សាតាមដានកម្មវិធីជាតិថ្នាក់រាជធានី ខេត្ត (PMA) ត្រូវបានលុបចោលចាប់ពីឆ្នាំ២០១៤ នេះតទៅ។ តួនាទី ភារកិច្ចនៃមុខតំណែងនេះត្រូវប្រគល់ទៅឱ្យទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់រាជធានី ខេត្ត (PPMA) ជាអ្នកទទួលខុសត្រូវ។

ថ្នាក់ក្រុង ស្រុក៖

ក/-មុខតំណែងដែលរក្សាទុក

១- ទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់ក្រុង ស្រុក

២- បុគ្គលិកសម្របសម្រួលក្រុមប្រឹក្សាថ្នាក់ក្រុង ស្រុក។

ខ/-មុខតំណែងដែលត្រូវកែសម្រួល

មុខតំណែងជំនួយការព័ត៌មានវិទ្យាក្រុង ស្រុក ត្រូវបានកែសម្រួលជាជំនួយការរដ្ឋបាល និងព័ត៌មានវិទ្យាថ្នាក់ក្រុង ស្រុកវិញ។ ចំពោះលក្ខខណ្ឌការងារ នីតិវិធី និងពេលវេលានៃការជ្រើសរើស លេខាធិការដ្ឋាន គ.ជ.អ.ប នឹងជូនដំណឹងពេលក្រោយ។ បុគ្គលិកជំនួយការព័ត៌មានវិទ្យាថ្នាក់ក្រុង ស្រុកទាំងអស់ដែលកំពុងបម្រើការងារបច្ចុប្បន្ន អាចដាក់ពាក្យសុំចូលបម្រើការងារជាជំនួយការរដ្ឋបាល និងព័ត៌មានវិទ្យាថ្នាក់ក្រុង ស្រុកបានបើសិនមានចំណាប់អារម្មណ៍។

គ/-មុខតំណែងបន្ថែមថ្មី

មុខតំណែងបុគ្គលិកគាំទ្រក្រុង ស្រុក ជាប្រភេទបុគ្គលិកកិច្ចសន្យាដែលត្រូវបានបង្កើតថ្មីសម្រាប់ផ្តល់ការគាំទ្របន្ថែមដល់រដ្ឋបាលក្រុង ស្រុកសម្រាប់ឆ្នាំ២០១៤ (០១ រូប សម្រាប់ ០១ ក្រុង ស្រុក)។ ចំពោះលក្ខខណ្ឌការងារ នីតិវិធី និងពេលវេលានៃការជ្រើសរើស លេខាធិការដ្ឋាន គ.ជ.អ.ប នឹងជូនដំណឹងពេលក្រោយ។

ថ្នាក់ខណ្ឌ៖

ក/-មុខតំណែងដែលរក្សាទុក

បុគ្គលិកសម្របសម្រួលក្រុមប្រឹក្សាខណ្ឌ។

ខ/-មុខតំណែងដែលលុបចោល

ជំនួយការព័ត៌មានវិទ្យាខណ្ឌ។

លេខាធិការដ្ឋាន គ.ជ.អ.ប នឹងរៀបចំកិច្ចប្រជុំជាមួយតំណាងរាជធានី ខេត្តទាំងអស់ នាពេលខាងមុខនេះ ដើម្បីធ្វើការណែនាំលម្អិតអំពីបញ្ហានានាពាក់ព័ន្ធនឹងកិច្ចការទាំងនេះ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើនេះ សូមឯកឧត្តមមេត្តាជ្រាប និងចាត់ចែងអនុវត្តតាមការគួរ ។

សូមឯកឧត្តមទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

**ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**

សក់ សេដ្ឋា

<u>ចម្លងជូន</u>

*-ឯកឧត្តមប្រធានក្រុមការងារគ្រប់គ្រង*
*អនុវត្ត អនុកម្មវិធីទី២ «ដើម្បីជូនជ្រាប»*
*-ឯកឧត្តមប្រធានក្រុមការងារគ្រប់គ្រង*
*អនុវត្ត អនុកម្មវិធីទី៤ «ដើម្បីជូនជ្រាប»*
*-សាលាក្រុង ស្រុក «សហការអនុវត្ត»*
*-ឯកសារ-កាលប្បវត្តិ*